ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
នាយកដ្ឋានរដ្ឋបាលទូទៅ
ចូល លេខ ៨០ ថ្ងៃទី ០៩ ខែ ០៦ ឆ្នាំ ២០ ម៉ោង ១៤:០០ បញ្ជូនទៅ ន.បុគ្គលិក

# ព្រះរាជក្រឹត្យ

នស/រកត/០៥២០/៥៨៤

## ស្ដីពី

## ការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

នាយកដ្ឋានបុគ្គលិក
លេខ ៤១៧
ចូលថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២០
ម៉ោង ០៣:២៥
បញ្ជូនទៅ ការិ.បុគ្គលិក

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានឈ្មោះថា **បេឡាជាតិសន្តិសុខសង្គម** សរសេរជាអក្សរកាត់ថា **ប.ស.ស.** និងសរសេរជាភាសាអង់គ្លេសថា National Social Security Fund សរសេរជាអក្សរកាត់ថា NSSF ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស គឺក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២ .-**

**ប.ស.ស.** ជានីតិបុគ្គលនៃនីតិសាធារណៈនិងមានថវិកាស្វយ័ត។ **ប.ស.ស.** ត្រូវបានធានានូវអត្ថិភាពការងារជានិរន្តរក្នុងគោលដៅការពារផលប្រយោជន៍ផ្នែកសន្តិសុខសង្គមដល់សមាជិករបស់ខ្លួន។

**ប.ស.ស.** មានទីស្នាក់ការកណ្ដាលនៅភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងមានសាខានៅតាមខេត្ត ក្រុង ស្រុក ខណ្ឌតាមការចាំបាច់។

**ប.ស.ស.** ត្រូវស្ថិតនៅក្រោមអានុភាពបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម។

**មាត្រា៣ .-**

**ប.ស.ស.** មានភារកិច្ចដូចខាងក្រោម៖

គ្រប់គ្រងនិងចាត់ចែងផ្នែកទាំងអស់នៃរបបសន្តិសុខសង្គម។

២- ធានាផ្ដល់តាវកាលិកសន្តិសុខសង្គមសម្រាប់សមាជិក **ប.ស.ស.** ក្នុងគោលដៅជួយសម្រាលការលំបាកក្នុងជីវភាពនៅពេលជួបប្រទះហានិភ័យជាយថាហេតុនានា ជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និកម្មភាពការងារ មាតុភាព ជំងឺ ឬគ្រោះថ្នាក់ ព្រមទាំងយថាភាពដទៃផ្សេងទៀត។

៣- ប្រមូលនិងគ្រប់គ្រងភាគទានរបបសន្តិសុខសង្គមនៃផ្នែកនីមួយៗ ព្រមទាំងប្រភពចំណូលដទៃផ្សេងទៀត។

៤- ចុះបញ្ជីនិងគ្រប់គ្រងលេខសម្គាល់សមាជិក **ប.ស.ស.**។

៥- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម ដោយសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **ប.ស.ស.**។

៦- អប់រំ ផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តវិធានការបង្ការហានិភ័យការងារ និងបង្ការសុខភាពសម្រាប់សមាជិក **ប.ស.ស.**។

៧- សិក្សា ស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។

៨- សិក្សា ស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ។

៩- ចុះកិច្ចព្រមព្រៀងនិងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

១០- សិក្សា វិភាគ និងវាយតម្លៃហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

១១- អនុវត្តសកម្មភាពពាក់ព័ន្ធនឹងសុខភាពនិងសង្គម ដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃសមាជិក **ប.ស.ស.**។

១២- ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

## ជំពូកទី២

## ការដឹកនាំនិងការគ្រប់គ្រង

### ផ្នែកទី១

### ក្រុមប្រឹក្សាភិបាលរបស់ ប.ស.ស.

**មាត្រា៤ .-**

**ប.ស.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលជាអង្គការដឹកនាំខ្ពស់បំផុតនិងមានបេសកកម្មតម្រង់ទិសការអនុវត្តនិងត្រួតពិនិត្យសកម្មភាពការងាររបស់ **ប.ស.ស.** ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម។

**មាត្រា៥ .-**

ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** មានចំនួន ១១ (ដប់មួយ) រូប ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - តំណាងក្រសួងមុខងារសាធារណៈ១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល១រូប | សមាជិក |

- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា១រូប សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប សមាជិក
- តំណាងនិយោជក២រូប សមាជិក
- តំណាងសមាជិក ប.ស.ស.២រូប សមាជិក
- អគ្គនាយក **ប.ស.ស.** សមាជិកអចិន្ត្រៃយ៍។

ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ត្រូវបង្កើតក្នុងរយៈពេលយ៉ាងយូរ១(មួយ)ខែ ក្រោយកាលបរិច្ឆេទចូលជាធរមាននៃព្រះរាជក្រឹត្យនេះ។

**មាត្រា៦ .-**

បេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការឬឥស្សរជនដែលមានលក្ខណសម្បត្តិនិងបទពិសោធន៍ដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរ
- បម្រើការងារយ៉ាងតិច៥ (ប្រាំ)ឆ្នាំ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋ
- មានសមត្ថភាពជំនាញជាអាទិ៍ក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច សុខាភិបាល ឬនីតិសាស្ត្រ។

បេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ដែលតំណាងនិយោជក និងតំណាងសមាជិក **ប.ស.ស.** ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ព្រមទាំងមានសមត្ថភាពក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច សុខាភិបាល ឬនីតិសាស្ត្រ និងពុំធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋ។

ក្រៅពីសមាជិកក្រុមប្រឹក្សាភិបាលអចិន្ត្រៃយ៍ សមាជិកក្រុមប្រឹក្សាដទៃទៀតត្រូវមានអាណត្តិ៣(បី)ឆ្នាំ ដែលត្រូវបានតែងតាំងនិងបញ្ចប់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ស្ថាប័ន ដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះ អាចបន្តសាជាថ្មីទៀតបានដោយអនុក្រឹត្យ ប៉ុន្តែមិនត្រូវលើសពី២(ពីរ)អាណត្តិឡើយ។

**មាត្រា៧ .-**

សមាជិកភាពក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ចប់មុនអាណត្តិតាមសំណើក្រសួងស្ថាប័នឬអង្គការវិជ្ជាជីវៈសាមី ក្នុងករណីដែលសមាជិកនោះមានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈ ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងឬស្ថាប័នមានសមត្ថកិច្ច ក្ស័យធន មិនព្រមបង់ភាគទានដែលខ្លួនទទួលបន្ទុកបានទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ **ប.ស.ស.** ឬបម្រើសេវាណាមួយឱ្យ **ប.ស.ស.** ទោះដោយចំពោះឬមិនចំពោះក្តី ឬត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ។

ក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួនរហូតដល់មានការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មីត្រូវតែងតាំងយ៉ាងយូរបំផុត១(មួយ)ខែ ក្រោយការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ចាស់។ មុនការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវរៀបចំសំណើទៅកាន់ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិថ្មី។ ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវមានបញ្ជាក់ពីអាណត្តិដែលសមាជិកនោះត្រូវទទួល។

សមាជិកក្រុមប្រឹក្សាភិបាលថ្មីដែលត្រូវតែងតាំងជំនួសកន្លែងទំនេរស្របតាមលក្ខខណ្ឌខាងលើ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាល។

លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** មានវិសមិតភាពជាមួយមុខងារជាអគ្គនាយក **ប.ស.ស.**។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាលត្រូវជាបន្ទុករបស់ **ប.ស.ស.** លើកលែងតែករណីដែលសមាជិកនោះបានប្រព្រឹត្តកំហុសដោយចេតនាឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ។

សមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

សមាជិកក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចចូលរួមប្រជុំតាមការអញ្ជើញ ប្រកាន់ខ្ជាប់នូវគោលជំហររាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួនជូនក្រសួង ស្ថាប័ន អង្គការវិជ្ជាជីវៈ ដែលខ្លួនតំណាងឱ្យ គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស.**។

**មាត្រា៨ .-**

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូបនឹងទទួលបានលាភការ និងការឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់ជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗខាងលើ អាចត្រូវផ្អាក ក្នុងករណីដែលសាមីសមាជិកក្រុមប្រឹក្សាភិបាលនោះពុំគោរពកាតព្វកិច្ចរបស់ខ្លួន ដែលមានជាអាទិ៍៖

១. ការគោរពក្រមសីលធម៌វិជ្ជាជីវៈនិងមនសិការវិជ្ជាជីវៈ។

២. ការគោរពបទបញ្ជានិងបទប្បញ្ញត្តិរបស់ **ប.ស.ស.**។

៣. ការបំពេញតួនាទីនិងភារកិច្ចនៅក្នុងក្រុមប្រឹក្សាភិបាល។

៤. ការអនុវត្តកាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថាប័ន អង្គភាព ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ។

ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាលដែលមានបទពិសោធន៍លើវិស័យពាក់ព័ន្ធនាទី រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស និងតំណាង

ដែគួរអភិវឌ្ឍឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

ប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់ឥស្សរជន មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គណនេយ្យករ និងលេខាកត់ត្រា ដែលបានចូលរួមប្រជុំក្រុមប្រឹក្សាភិបាល ត្រូវសម្រេចជាគោលការណ៍ដោយក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ស្របតាមលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស.**។

**មាត្រា៩ .-**

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំ តម្រង់ទិសការអនុវត្តសកម្មភាពការងារ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ប.ស.ស.**។

ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះក្រុមប្រឹក្សាភិបាលត្រូវៈ

- ពិនិត្យ និងអនុម័តបទបញ្ញាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស.**
- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍរបស់ **ប.ស.ស.** ទាំងសម្រាប់រយៈពេលមធ្យមទាំងសម្រាប់រយៈពេលវែង
- ពិនិត្យ និងអនុម័តគម្រោងថវិកានិងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ **ប.ស.ស.**
- ពិនិត្យនិងអនុម័តរបាយការណ៍គ្រប់គ្រង **ប.ស.ស.** របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ
- កំណត់ការរៀបចំរចនាសម្ព័ន្ធនិងភារកិច្ចទូទៅរបស់អង្គភាពចំណុះ **ប.ស.ស.**
- ជំរុញដំណើរការរបស់ក្រុមប្រឹក្សាឬគណៈកម្មាធិការជំនាញចំណុះ **ប.ស.ស.**
- កំណត់នូវនីតិវិធីនៃការជ្រើសរើស ការដំឡើងឋានន្តរស័ក្តិ ឬការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗដល់បុគ្គលិកតាមសំណើរបស់អគ្គនាយក **ប.ស.ស.**
- ពិនិត្យ និងអនុម័តលើសំណើសុំកំណត់ក្របខ័ណ្ឌនិងចំនួនបុគ្គលិកប្រចាំឆ្នាំរបស់អគ្គនាយក **ប.ស.ស.**
- ពិនិត្យនិងអនុម័តលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យនិងអនុម័តលើសំណើកំណត់តាវកាលិកសន្តិសុខសង្គម
- ធ្វើការវាយតម្លៃលើលទ្ធផលសម្រេចបានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើកវិធានការកែតម្រូវសម្រាប់អនុវត្តបន្ត។

**មាត្រា១០ .-**

យ៉ាងយូរ១(មួយ)ខែ ក្រោយការបង្កើតក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូងដែលរបៀបវារៈសំខាន់ គឺការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ **ប.ស.ស.** និងការរៀបចំបទបញ្ញាផ្ទៃក្នុងនៃ **ប.ស.ស.**។

ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងប្រជុំវិសាមញ្ញតាមគំនិតផ្តួចផ្តើមរបស់ប្រធានក្រុមប្រឹក្សាភិបាលឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលឬតាមសំណើរបស់អគ្គនាយក **ប.ស.ស.** តាមការចាំបាច់។

សម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំចាំបាច់ត្រូវដាក់បញ្ចូលរបៀបវារៈទាក់ទងនឹងការអនុវត្តថវិកា ការពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ។

អគ្គនាយក **ម.ស.ស.** ត្រូវចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសមន្ត្រីម្នាក់ជាលេខាធិការនៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។ លេខាធិការនេះពុំមានសិទ្ធិបោះឆ្នោតទេ។

ក្រុមប្រឹក្សាភិបាលធ្វើការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈត្រូវបានជូនដំណឹងមុនយ៉ាងតិច ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការងារដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាលនិងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា២៩នៃព្រះរាជក្រឹត្យនេះ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលតែមិនមានសិទ្ធិបោះឆ្នោត។

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលលើសពី៥០(ហាសិប)ភាគរយ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមានពុំអាចឱ្យគេជំនួសបានឡើយ។

ប្រសិនបើកូរ៉ុមមិនគ្រប់គ្រាន់ នោះប្រធានក្រុមប្រឹក្សាភិបាលអាចកោះអញ្ជើញប្រជុំជាថ្មីក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃក្រោយ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី១ប៉ុណ្ណោះ។

សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់ប្រធាននិងរក្សាទុកនៅទីស្នាក់ការរបស់ **ម.ស.ស.**។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវរៀបចំនិងផ្ញើសេចក្តីព្រាងកំណត់ហេតុជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល២(ពីរ)ថ្ងៃក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការងារគិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល១០(ដប់)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំប្រធានក្រុមប្រឹក្សាភិបាលត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលទទួលបានការកែតម្រូវឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាលនិងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើត្រូវបញ្ជូនក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់និងជូន[illegible]ប្រជុំ។

[illegible]ប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំត្រូវធ្វើឡើងជាចាំបាច់ដោយមិនត្រូវរំលងខែបន្ទាប់[illegible]ត្រីមាស ឆមាស និងឆ្នាំ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាល ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំគឺជា[illegible]ទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល។

## ផ្នែកទី២

## អង្គភាពប្រតិបត្តិរបស់ ប.ស.ស.

**មាត្រា១១ .-**

**ប.ស.ស.** ត្រូវចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃដោយអគ្គនាយក១(មួយ)រូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។ អគ្គនាយក **ប.ស.ស.** មានតួនាទីជានាយកប្រតិបត្តិ។ ការតែងតាំងអគ្គនាយក **ប.ស.ស.** ត្រូវធ្វើឡើងយ៉ាងយូរ១(មួយ)ខែ ក្រោយការចូលជាធរមាននៃព្រះរាជក្រឹត្យនេះ។

មុខងារជាអគ្គនាយក **ប.ស.ស.** មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងជាមួយមុខងារជាប្រធានក្រុមប្រឹក្សាភិបាល។ យ៉ាងយូរ១(មួយ)ខែក្រោយការតែងតាំងអគ្គនាយក **ប.ស.ស.** ត្រូវចាត់ចែងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។

**មាត្រា១២ .-**

អគ្គនាយក **ប.ស.ស.** ជាតំណាងរបស់ **ប.ស.ស.** ក្នុងការទំនាក់ទំនងជាមួយតតិយជន។

អគ្គនាយក **ប.ស.ស.** បំពេញមុខងារនិងភារកិច្ចដូចតទៅះ

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំសេចក្តីព្រាងបទបញ្ញាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ **ប.ស.ស.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ **ប.ស.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំរបាយការណ៍គ្រប់គ្រង **ប.ស.ស.** របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតក្រោមការកាន់កាប់និងប្រើប្រាស់របស់ **ប.ស.ស.** ដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- បញ្ជូនបញ្ជីសារពើភណ្ឌទាំងនោះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុកនិងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជាទៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់នូវភារកិច្ចដែលត្រូវបានប្រគល់ជូនអង្គភាពចំណុះនានារបស់ **ប.ស.ស.**

- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងការជ្រើសរើសមន្ត្រីរាជការស៊ីវិល ជូនក្រុមប្រឹក្សាភិបាលពិនិត្យអនុម័តនិងស្នើសុំទៅក្រសួងមុខងារសាធារណៈដើម្បីពិនិត្យនិងសម្រេច
- លើកសំណើស្តីពីការរៀបចំ ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនបុគ្គលិកជាប់កិច្ចសន្យារបស់ **ប.ស.ស.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកគ្រប់ប្រភេទជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាលនិងគ្រប់គ្រងទាំងឡាយដទៃទៀតដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

អគ្គនាយក **ប.ស.ស.** ត្រូវធ្វើសំណើទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីស្នើសុំរាជរដ្ឋាភិបាលតែងតាំងអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។ អគ្គនាយករង ត្រូវមានចំណេះដឹងលើផ្នែកបច្ចេកទេសតាមវិស័យនីមួយៗដែលត្រូវទទួលគ្រប់គ្រង។

**មាត្រា១៣ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី ៣

## បុគ្គលិករបស់ ប.ស.ស.

**មាត្រា១៤ .-**

បុគ្គលិករបស់ **ប.ស.ស.** ជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានផ្ទេរឬជ្រើសរើសថ្មីតាមសំណើរបស់អគ្គនាយក **ប.ស.ស.**។

ការផ្ទេរឬការជ្រើសរើសថ្មីឱ្យមកបម្រើការនៅ **ប.ស.ស.** របស់មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈត្រូវឆ្លងតាមការប្រឡងជ្រើសរើសជាចាំបាច់ ដែលការប្រឡងនេះត្រូវអនុវត្តដោយ **ប.ស.ស.** ផ្ទាល់។

**ប.ស.ស.** អាចត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស.**។

បុគ្គលិកជាប់កិច្ចសន្យារបស់ **ប.ស.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

បទបញ្ជាផ្ទៃក្នុងទាក់ទងនឹងបុគ្គលិកជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារ

បុគ្គលិកជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈដែលបំពេញភារកិច្ចនៅ **ប.ស.ស.** ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការរដ្ឋស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗក្រៅពីថវិការរដ្ឋជូនបុគ្គលិកជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈរបស់ **ប.ស.ស.** ត្រូវសម្រេចដោយអគ្គនាយក **ប.ស.ស.** អនុលោមតាមគោលការណ៍កំណត់ក្នុងលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស.**។

ការផ្តល់ប្រាក់ឈ្នួល លាភការ ឬអត្ថប្រយោជន៍ផ្សេងៗជូនបុគ្គលិកជាប់កិច្ចសន្យាជាថវិកាផ្ទាល់របស់ **ប.ស.ស.** ត្រូវសម្រេចដោយអគ្គនាយក **ប.ស.ស.** អនុលោមតាមគោលការណ៍កំណត់ក្នុងលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស.**។

## ផ្នែកទី ៤
## ទ្រព្យសម្បត្តិរបស់ ប.ស.ស.

**មាត្រា១៥ .-**

**ប.ស.ស.** មានបុព្វសិទ្ធិនៃអំណាចសាធារណៈក្នុងការប្រមូលភាគទាន ការឱ្យសងបំណុល និងការការពារទ្រព្យសម្បត្តិ។

**ប.ស.ស.** មានឯកសិទ្ធិលើទ្រព្យទាំងអស់របស់កូនបំណុលក្នុងលំដាប់បន្ទាប់ពីសិទ្ធិលើបំណុលរបស់កម្មករនិយោជិត។

នីតិវិធីនៃការអនុវត្តបុព្វសិទ្ធិនិងការទារបំណុលរបស់ **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៦ .-**

**ប.ស.ស.** ត្រូវទទួលខុសត្រូវកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ប.ស.ស.** មានទ្រព្យសម្បត្តិដែលរួមមាន៖

ក. ធនធានគ្រាដំបូងទទួលបានពីរដ្ឋដែលមានបញ្ជាក់ក្នុងតារាងតុល្យការភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួងរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ។ តារាងតុល្យការត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួមជាមួយនឹងតារាងឧបសម្ព័ន្ធនានា។

ខ. ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលអាចរកបានក្រោយថ្ងៃបង្កើត **ប.ស.ស.** ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ប.ស.ស.** ត្រូវបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ **ប.ស.ស.**។ អគ្គនាយក **ប.ស.ស.** ដែលជាប្រធាន និងសមាជិកដទៃទៀតនៃគណៈកម្មការនេះ ត្រូវទទួលខុសត្រូវនិងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌដែលបានរៀបចំរួច។ ការរៀបចំបញ្ជីសារពើភណ្ឌត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗឱ្យបានពេញលេញនិងគ្រប់ជ្រុងជ្រោយដោយអនុលោមតាមបែបបទ នីតិវិធីនិងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប.ស.ស.** មានកាតព្វកិច្ចរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងនិងថយចុះប្រចាំឆ្នាំនីមួយៗ ឱ្យបានត្រឹមត្រូវដោយយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋភ្ជាប់នឹងតារាងតុល្យការនៃធនធានគ្រាដំបូងជាគោល រួចហើយត្រូវផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអាណាព្យាបាលទាំងពីរយ៉ាងយូរនៅចុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។

**ប.ស.ស.** អាចធ្វើការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីចលនទ្រព្យនិងអចលនទ្រព្យបានលុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌនិងនីតិវិធីនៃការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** និងមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណី **ប.ស.ស.** ត្រូវរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយអនុក្រឹត្យ ទ្រព្យសកម្មដែលជាចលនទ្រព្យនិងអចលនទ្រព្យរបស់ **ប.ស.ស.** ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋ ក្រោយពីការជម្រះបញ្ជីតាមនីតិវិធីជាធរមាន។ ចំពោះទ្រព្យសកម្មជារូបិយវត្ថុត្រូវបង្វែរចូលគណនីទោលរបស់រតនាគារជាតិ។

## ផ្នែកទី ៥

## ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យរបស់ ប.ស.ស.

**មាត្រា១៧ .-**

**ប.ស.ស.** ត្រូវមានគណនេយ្យភាពលើការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ។

ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យរបស់ **ប.ស.ស.** ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨ .-**

អគ្គនាយក **ប.ស.ស.** ជាអាណាប័កដើមខ្សែនៃថវិការបស់ **ប.ស.ស.** ដោយមានសិទ្ធិអំណាចដូចតទៅៈ

- បញ្ជានិងជម្រះចំណូល
- បញ្ជាចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់។

**មាត្រា១៩ .-**

ប្រភពធនធានរបស់ **ប.ស.ស.** មានប្រភពមកពីៈ

- ការបង់ភាគទានពីរដ្ឋ និយោជក និងសមាជិក **ប.ស.ស.**
- ផលដែលបានមកពីការវិនិយោគ
- អំណោយឬអច្ច័យទាន និងប្រភពស្របច្បាប់ផ្សេងទៀត។

## ផ្នែកទី ៦

## របបសារពើពន្ធរបស់ ប.ស.ស.

**មាត្រា២០ .-**

កិច្ចប្រតិបត្តិការរបស់ខ្លួន **ប.ស.ស.** ត្រូវរួចផុតពីការបង់ពន្ធ និងអាករគ្រប់ប្រភេទ។ ក្នុងករណីប្រតិបត្តិការរបស់ **ប.ស.ស.** ដែលមានចរិតជាពាណិជ្ជកម្ម ហើយមានគោលដៅរកផលចំណេញ ត្រូវជាប់ពន្ធអាករតាមច្បាប់និងបទប្បញ្ញត្តិពន្ធដារជាធរមាន។

## ផ្នែកទី៧

## ការងារលទ្ធកម្មរបស់ ប.ស.ស.

**មាត្រា២១ .-**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មក្នុង **ប.ស.ស.** ត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី ៣

## អាណាព្យាបាលភាព

**មាត្រា២២ .-**

**ប.ស.ស.** មានអាណាព្យាបាលពីរដូចខាងក្រោម៖

១. អាណាព្យាបាលបច្ចេកទេស គឺក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. អាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៣ .-**

**ប.ស.ស.** ត្រូវផ្តល់ជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ **ប.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការពិនិត្យនិងអនុម័តដោយក្រុមប្រឹក្សាភិបាល នូវឯកសារដូចខាងក្រោម៖

- កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍ **ប.ស.ស.**
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស.**
- របាយការណ៍គ្រប់គ្រង **ប.ស.ស.** របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំរបាយការណ៍លទ្ធកម្មសាធារណៈ និងរបាយការណ៍ហិរញ្ញវត្ថុ។

បន្ទាប់ពីទទួលបានឯកសារខាងលើ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ **ប.ស.ស.** ត្រូវចាត់ការបន្តតាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៤ .-**




អាណាព្យាបាលបច្ចេកទេសមានភារកិច្ចដូចខាងក្រោម៖

១. កំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ ស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមសម្រាប់ **ប.ស.ស.** អនុវត្ត

- ត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់ **ប.ស.ស.**
- ដាក់ចេញវិធានការកែលម្អនានាពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់ **ប.ស.ស.**។

**មាត្រា២៥ .-**

ក្នុងករណីដែលក្រុមប្រឹក្សាភិបាលឬអគ្គនាយក **ប.ស.ស.** ពុំប្រតិបត្តិតាមបណ្តាវិធានដែលមានចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស.** អាណាព្យាបាលបច្ចេកទេសអាចចាត់ចែងការងារចេញសេចក្តីសម្រេចនិងអាចប្រើប្រាស់វិធានការចាំបាច់ទាំងអស់ បន្ទាប់ពីបានធ្វើការណែនាំនិងដាក់កំហិតជាលាយលក្ខណ៍អក្សររួចមក។

## ផ្នែកទី២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា២៦ .-**

អាណាព្យាបាលហិរញ្ញវត្ថុមានភារកិច្ចៈ

- ពិនិត្យនិងផ្តល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍ **ប.ស.ស.**
- ពិនិត្យនិងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស.**
- ពិនិត្យនិងអនុម័តផែនការលទ្ធកម្មរបស់ **ប.ស.ស.**
- ពិនិត្យនិងសម្រេចលើការចាត់ចែងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋនិងការជម្រះបញ្ជីសារពើភណ្ឌ
- ពិនិត្យនិងផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យនិងសម្រេចលើសេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យនិងសម្រេចឬផ្តល់ការយល់ព្រមលើឯកសារផ្សេងទៀត តាមសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអគ្គនាយក **ប.ស.ស.** ស្របតាមបទប្បញ្ញត្តិជាធរមាន។
- រៀបចំ និងដាក់ឱ្យអនុវត្តនូវវិធាន និងនីតិវិធីចំណូល ចំណាយ បទដ្ឋានចំណូល ចំណាយ និងបទដ្ឋានគតិយុត្តទាំងឡាយដទៃទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ **ប.ស.ស.**។

**មាត្រា២៧ .-**

សេចក្តីសម្រេចរបស់អាណាព្យាបាលបច្ចេកទេស អគ្គនាយក **ប.ស.ស.** ឬក្រុមប្រឹក្សាភិបាល ដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា២៦នៃព្រះរាជក្រឹត្យនេះ ពុំមានអានុភាពអនុវត្តឡើយ ក្នុងករណីដែលពុំមានការយល់ព្រមពីអាណាព្យាបាលហិរញ្ញវត្ថុ ។

ក្នុងករណីអាណាព្យាបាលហិរញ្ញវត្ថុជំទាស់លើសេចក្តីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាណាព្យាបាលហិរញ្ញវត្ថុត្រូវផ្ញើជូនអគ្គនាយក **ប.ស.ស.** នូវការជំទាស់របស់ខ្លួនដោយបញ្ជាក់នូវមូលហេតុច្បាស់លាស់។ អគ្គនាយក **ប.ស.ស.** និងក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** ត្រូវពិនិត្យនិងដោះស្រាយឱ្យបានឆាប់ជូនករណីដែលបានលើកឡើងនោះដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៨ .-**

អាណាព្យាបាលហិរញ្ញវត្ថុអាចលុបឬផ្អាកការអនុវត្តសេចក្ដីសម្រេចពាក់ព័ន្ធទិដ្ឋភាពហិរញ្ញវត្ថុរបស់អាណាព្យាបាលបច្ចេកទេស អគ្គនាយក **ប.ស.ស.** ឬក្រុមប្រឹក្សាភិបាល ក្នុងករណីដែលៈ

- សេចក្ដីសម្រេចរបស់អគ្គនាយក **ប.ស.ស.** ឬក្រុមប្រឹក្សាភិបាល ផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- សេចក្ដីសម្រេចមានការពាក់ព័ន្ធនឹងបណ្ដឹងផ្សេងៗដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោលឬការផ្អាកការអនុវត្តនេះ ត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់និងត្រូវជូនដំណឹងដល់ក្រសួងអាណាព្យាបាលបច្ចេកទេសអគ្គនាយក **ប.ស.ស.** ដែលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា២៩ .-**

អាណាព្យាបាលហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ១(មួយ)រូប ប្រចាំ **ប.ស.ស.** ដើម្បីបំពេញមុខងារដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី ៤

## ការត្រួតពិនិត្យ

**មាត្រា៣០ .-**

**ប.ស.ស.** ត្រូវស្ថិតនៅក្រោមការធ្វើសវនកម្មដោយអាជ្ញាធរសវនកម្មជាតិស្របតាមបទប្បញ្ញត្តិផ្សេងៗជាធរមាន។ ក្នុងករណីចាំបាច់ និយ័តករសន្តិសុខសង្គមឬក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** អាចស្នើឱ្យមានការធ្វើសវនកម្មពីស្ថាប័នឯករាជ្យណាមួយ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**មាត្រា៣១ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការបង្កើត **ប.ស.ស.** និងកិច្ចប្រតិបត្តិការរបស់ **ប.ស.ស.** ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា៣២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ព្រះបរមរាជវាំង

**មាត្រា៣៣ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៩កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២០

នស/រកត/០៥២០/៦០០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**